# ឯកសិទ្ធិនៃការអធិស្ឋាន

*ដោយ អែលឌើរ ជេ ដឺន ខូនីស*
*នៃពួកចិតសិប*

បងប្អូនប្រុសស្រីជាទីស្រឡាញ់របស់ខ្ញុំ ព្រះជាព្រះវរបិតាយើង ពុំមែនជាអារម្មណ៍ ឬគំនិត ឬកម្លាំងមួយនោះទេ ។ ដូចដែលព្រះគម្ពីរបង្រៀន ទ្រង់ជាអង្គដ៏បរិសុទ្ធ មានព្រះភ័ក្រ្ត និងព្រះហស្ត និងរូបកាយដែលរស់ឡើងវិញដ៏រុងរឿងមួយ ។ ទ្រង់គឺពិត ទ្រង់ស្គាល់យើងម្នាក់ៗ ហើយទ្រង់ស្រឡាញ់យើងគ្រប់គ្នា ។ ទ្រង់ចង់ប្រទានពរដល់យើង ។

ព្រះយេស៊ូវមានបន្ទូលថា ៖ « ក្នុងពួកអ្នករាល់គ្នា បើកូនសូមនំប៉័ង តើមានអ្នកណានឹងឲ្យថ្មដល់វា ? ឬបើវាសូមត្រី តើនឹងឲ្យពស់វិញឬអី ? ចុះបើអ្នករាល់គ្នាដែលអាក្រក់ អ្នកចេះឲ្យរបស់ល្អដល់កូនខ្លួនដូច្នេះ នោះចំណង់បើព្រះវរបិតានៃអ្នក ដែលទ្រង់គង់នៅស្ថានសួគ៌ ទ្រង់នឹងប្រទានរបស់ល្អ មកអស់អ្នកដែលសូម តើជាងអម្បាលម៉ានទៅទៀត ? » ( ម៉ាថាយ 7:9--11 ) ។

ប្រហែលជាបទពិសោធន៍ផ្ទាល់ខ្លួនមួយ នឹងជួយពន្យល់ពីគោលការណ៍នេះ ។ កាលខ្ញុំនៅជាគ្រូពេទ្យកំពុងចុះស្តាជ័យក្មេងម្នាក់ នៅមន្ទីរពេទ្យកុមារ បូស្តុន ខ្ញុំបានធ្វើការច្រើនម៉ោង ហើយភាគច្រើន គឺធ្វើដំណើរដោយកង់ពីមន្ទីរពេទ្យ ទៅផ្ទះយើងនៅវីតធើរថោន រដ្ឋម៉ាស្សាឈូសេត  ដោយសារភរិយា និងកូនៗយើងត្រូវការឡាន ។ នាល្ងាចមួយ ខ្ញុំកំពុងជិះកង់ទៅផ្ទះ បន្ទាប់ពីធ្វើការយ៉ាងយូរក្នុងមន្ទីរពេទ្យ ទាំងមានអារម្មណ៍ហត់នឿយ និងឃ្លានខ្លាំង ហើយបាក់ទឹកចិត្តបន្តិចផង ។ ខ្ញុំដឹងថា ពេលខ្ញុំទៅដល់ផ្ទះ ខ្ញុំមិនត្រឹមតែត្រូវផ្តល់ពេលវេលា និងថាមពលរបស់ខ្ញុំ ដល់ភរិយា និងកូនតូចទាំងបួនរបស់ខ្ញុំប៉ុណ្ណោះទេ តែខ្ញុំត្រូវផ្តល់ដោយឥរិយាបទរីករាយផងដែរ ។ និយាយដោយត្រង់ទៅ ខ្ញុំពិបាកនឹងបន្តធាក់ឈ្នាន់កង់ឲ្យទៅមុខទៀតផង ។

នៅតាមផ្លូវដែលខ្ញុំជិះកាត់នោះ មានហាងលក់មាន់បំពងមួយ ហើយខ្ញុំមានអារម្មណ៍ថា ខ្ញុំនឹងមិនសូវឃ្លាន ហើយហត់នឿយទេ បើខ្ញុំឈប់មួយភ្លែតហូបមាន់មួយដុំ ។ ខ្ញុំបានដឹងថា គេលក់ភ្លៅមាន់បញ្ចុះតម្លៃ មួយដុំតែ 29 សេន ប៉ុណ្ណោះ តែពេលខ្ញុំមើលក្នុងកាបូបលុយ ខ្ញុំមានទាំងអស់តែ 5 សេនប៉ុណ្ណោះ ។ ពេលខ្ញុំបន្តធាក់កង់ទៅមុខទៀត ខ្ញុំបានទូលដល់ព្រះពីស្ថានភាពរបស់ខ្ញុំ ហើយដោយក្តីមេត្តាទ្រង់ សូមទ្រង់ជួយខ្ញុំឲ្យរកបានកាក់ 25 សេនទៀត នៅតាមផ្លូវ ។ ខ្ញុំបានទូលទ្រង់ថា ខ្ញុំមិនត្រូវការឲ្យការណ៍នេះកើតឡើងសម្រាប់ជាទីសម្គាល់មួយនោះទេ តែថា ខ្ញុំមានអំណរគុណជាខ្លាំង បើទ្រង់មានព្រះទ័យប្រទានដល់ខ្ញុំនូវពរជ័យនេះ ។

ខ្ញុំកាន់តែមានបំណងចាប់ផ្តើមសម្លឹងទៅក្រោម តែមិនឃើញអ្វីសោះ ។ ពេលខ្ញុំជិះកង់ ដោយព្យាយាមរក្សានូវឥរិយាបទដែលនៅតែមានជំនឿ ហើយក៏ស្ទាប់បង្អាប់ដែរនោះ ខ្ញុំបានទៅដល់ហាងនោះ ។ ស្ទើរតែចំមុខផ្លូវពីហាងមាន់នោះ ខ្ញុំបានឃើញកាក់ 25 សេន នៅលើដី ។ ខ្ញុំបានរើសវាឡើង ដោយការដឹងគុណ និងអារម្មណ៍ធូរស្បើយ បានទិញមាន់ ញ៉ាំឆ្អាញ់គ្រប់ម៉ាត់ ហើយបានជិះកង់ទៅផ្ទះដោយរីករាយ ។

ដោយក្តីមេត្តាទ្រង់ នោះព្រះនៃស្ថានសួគ៌ ជាអង្គបង្កើត និងអង្គគ្រប់គ្រងលើអ្វីៗទាំងអស់គ្រប់ទីកន្លែង បានឮការអធិស្ឋានពីការណ៍ដ៏តូចបំផុត ។ ប្រហែលមានអ្នកសួរថា ហេតុអ្វីទ្រង់ខ្វល់ពីរឿងតូចតាចនោះ ។ ខ្ញុំត្រូវបានដឹកនាំឲ្យជឿថា ព្រះវរបិតាសួគ៌យើងស្រឡាញ់យើងខ្លាំងណាស់ រហូតដល់អ្វីដែលសំខាន់ដល់យើង ក៏សំខាន់ដល់ទ្រង់ដែរ ព្រោះទ្រង់ស្រឡាញ់យើង ។ ចុះទម្រាំតែការណ៍ដ៏ធំដែលយើងសុំ ដែលត្រឹមត្រូវនោះ តើទ្រង់រឹតតែចង់ជួយយើងយ៉ាងណាទៅ ( នីហ្វៃទី3 18:20 ) ?

កុមារតូចៗ យុវវ័យ និងមជ្ឈិមវ័យក៏ដូចគ្នាដែរ សូមជឿថា ព្រះវរបិតាជាទីស្រឡាញ់របស់អ្នកចង់ប្រទានពរដល់ *អ្នក* ខ្លាំងណាស់ ។ តែដោយសារទ្រង់នឹងមិនបំពានលើសិទ្ធិសេរីភាពរបស់យើង នោះយើងត្រូវតែសុំជំនួយទ្រង់ ។ ជាទូទៅ ការណ៍នេះធ្វើឡើងតាមការអធិស្ឋាន ។ ការអធិស្ឋានជាអំណោយដ៏មានតម្លៃបំផុតមួយរបស់ព្រះដល់មនុស្ស ។

ក្នុងឱកាសមួយ សិស្សរបស់ព្រះយេស៊ូវទូលថា « ព្រះអម្ចាស់អើយ សូមទ្រង់បង្រៀនយើងខ្ញុំ ឲ្យចេះអធិស្ឋានផង » ( លូកា 11:1 ) ។ ជាការឆ្លើយតបព្រះយេស៊ូវបានប្រទានគំរូដែលជាការណែនាំមួយ ពីគោលការណ៍ដ៏សំខាន់នៃការអធិស្ឋាន ( សូមមើល Russell M. Nelson « Lessons from the Lord's Prayers » *Liahona* និង *Ensign*  ខែ ឧសភា 2009 ទំព័រ 46--49 សូមមើលផងដែរ ម៉ាថាយ 6:9--13, លូកា 11:1--4 ) ។ យោងតាមគំរូរបស់ព្រះយេស៊ូវ ៖

យើងចាប់ផ្ដើមដោយការទូលទៅកាន់ព្រះវរបិតាសួគ៌យើង ៖ « ឱព្រះវរបិតានៃយើងខ្ញុំ ដែលគង់នៅស្ថានសួគ៌អើយ » ( ម៉ាថាយ 6:9; លូកា 11:2 ) ។ វាជាឯកសិទ្ធិរបស់យើង ដើម្បីទូលទៅកាន់ព្រះវរបិតាយើងដោយផ្ទាល់តែម្ដង ។ យើងមិនអធិស្ឋានទៅកាន់នរណាម្នាក់ផ្សេងទៀតនោះទេ ។ សូមចងចាំថា យើងត្រូវបានទូន្មានឲ្យជៀសវាងពីការពោលពាក្យផ្ទួនៗ រួមទាំងការប្រើព្រះនាមព្រះវរបិតាញឹកញាប់ពេក ពេលយើងអធិស្ឋាន ។[1]

« សូមឲ្យព្រះនាមទ្រង់បានបរិសុទ្ធ » ( ម៉ាថាយ 6:9; លូកា 11:2 ) ។ ព្រះយេស៊ូវមានបន្ទូលទៅព្រះបិតាទ្រង់ ដោយឥរិយាបទនៃការថ្វាយបង្គំ ដោយស្គាល់នូវភាពមហិមារបស់ទ្រង់ ហើយថ្វាយការសរសើរតម្កើង និងអំណរគុណដល់ទ្រង់ ។ ប្រាកដណាស់ គារវភាពដល់ព្រះ និងការស្មោះត្រង់ និងការអរព្រះគុណដ៏ជាក់លាក់បែបនេះ ជាផ្នែកដ៏សំខាន់បំផុតមួយនៃការអធិស្ឋានដ៏មានប្រសិទ្ធភាព ។

« សូមឲ្យរាជទ្រង់បានមកដល់ ។ សូមឲ្យព្រះហឫទ័យទ្រង់បានសម្រេច » ( ម៉ាថាយ 6:10; លូកា 11:2 ) ។ យើងទទួលស្គាល់ដោយសេរី ពីការពឹងផ្អែករបស់យើងទៅព្រះអម្ចាស់ ហើយបង្ហាញពីបំណងរបស់យើងក្នុងការធ្វើតាមព្រះទ័យទ្រង់ ទោះជាវាមិនដូចជាបំណងរបស់យើងក្ដី ។ សេចក្ដីណែនាំដល់បទគម្ពីរទាំងឡាយរបស់យើងពន្យល់ថា ៖ « ការអធិស្ឋានជាទង្វើ ដែលព្រះទ័យនៃព្រះវរបិតា និងបំណងនៃបុត្រនោះ គឺចូលជាផ្លូងតែមួយ ។ គោលបំណងនៃការអធិស្ឋាន គឺមិនមែនដើម្បីផ្លាស់ប្ដូរព្រះទ័យនៃព្រះនោះទេ ប៉ុន្តែដើម្បីទទួលបាននូវពរជ័យទាំងឡាយ សម្រាប់ខ្លួនយើង និងអ្នកដទៃដែលព្រះមានព្រះទ័យរួចជាស្រេចទៅហើយថានឹងប្រទាន តែវាតាមលក្ខខ័ណ្ឌដែលយើងសុំប៉ុណ្ណោះ » ( សេចក្ដីណែនាំដល់បទគម្ពីរទាំងឡាយ « ការអធិស្ឋាន » ) ។

« សូមប្រទានអាហារដែលយើងខ្ញុំត្រូវការនៅថ្ងៃនេះ » ( ម៉ាថាយ 6:11, សូមមើល លូកា 11:3 ) ។ យើងសូមអ្វីៗដែលយើងចង់បានពីព្រះ ។ ភាពស្មោះត្រង់គឺជាការចាំបាច់ ក្នុងការសុំអ្វីៗពីព្រះ ។ ឧទាហរណ៍ វាមិនមែនជាភាពស្មោះត្រង់ទាំងស្រុងនោះទេ ដើម្បីសុំព្រះឲ្យជួយក្នុងការប្រលងមួយនៅសាលា ប្រសិនបើខ្ញុំមិនបានយកចិត្តទុកដាក់ក្នុងថ្នាក់រៀន មិនបានធ្វើលំហាត់ ឬមិនបានរៀនសម្រាប់ការប្រលងនោះ ។ ជា ញឹកញាប់ ពេលខ្ញុំអធិស្ឋាន ព្រះវិញ្ញាណបំផុសដល់ខ្ញុំឲ្យទទួលស្គាល់ថា មានអ្វីបន្ថែមទៀតដែលខ្ញុំគប្បីធ្វើ ដើម្បីទទួលជំនួយដែលខ្ញុំកំពុងសុំពីព្រះអម្ចាស់ ។ បន្ទាប់មក ខ្ញុំត្រូវតាំងចិត្ត និងធ្វើផ្នែករបស់ខ្ញុំ ។ វាជាការផ្ទុយទៅនឹងផែនការនៃព្រះ ដែលព្រះត្រូវធ្វើសម្រាប់យើង នូវអ្វីដែលយើងអាចធ្វើដោយខ្លួនឯង ។

« សូមអត់ទោសសេចក្ដីកំហុសរបស់យើងខ្ញុំ » ( ម៉ាថាយ 6:12 ) ឬក្នុងខមួយទៀតថា « សូមអត់ទោសបាបយើងខ្ញុំ » ( លូកា 11:4 ) ។ ផ្នែកដ៏ចាំបាច់ និងជូនកាលត្រូវបានភ្លេច ក្នុងការអធិស្ឋានផ្ទាល់ខ្លួននោះគឺ ការប្រែចិត្ត ។ ដើម្បីឲ្យការប្រែចិត្តសម្រេចបាននោះ វាត្រូវតែជាក់លាក់ ស្មោះត្រង់ និងអត់ធ្មត់ ។

« ដូចជាយើងខ្ញុំបានអត់ទោសដល់អស់អ្នកដែលធ្វើខុសនឹងយើងខ្ញុំដែរ » ( ម៉ាថាយ 6:12, សូមមើល លូកា 11:4 ) ។ ព្រះអង្គសង្គ្រោះបានបង្កើតនូវទំនាក់ទំនងដ៏ច្បាស់មួយ រវាងការបានអភ័យទោសដល់បាបរបស់យើង និងការអភ័យទោសដល់អ្នកដទៃដែលបានធ្វើខុសចំពោះយើង ។ ជូនកាលកំហុសដែលអ្នកដទៃបានធ្វើចំពោះយើង គឺឈឺចាប់ខ្លាំងណាស់ ហើយពិបាកខ្លាំងណាស់នឹងអភ័យទោស ឬបំភ្លេច ។ ខ្ញុំមានអំណរគុណសម្រាប់ការលួងលោម និងការព្យាបាល ដែលខ្ញុំបានរកឃើញក្នុងការអញ្ជើញរបស់ព្រះអម្ចាស់ ឲ្យលះបង់ការឈឺចាប់របស់យើង ហើយប្រគល់វាដល់ទ្រង់វិញ ។ ក្នុង គោលលទ្ធិ និងសេចក្ដីសញ្ញាកណ្ឌទី 64 ទ្រង់មានបន្ទូលថា ៖ « យើងជាព្រះអម្ចាស់នឹងអត់ទោសដល់អ្នកណា ដែលយើងនឹងអត់ទោស ប៉ុន្តែរីឯអ្នកវិញគឺតម្រូវឲ្យអត់ទោសដល់មនុស្សទាំងអស់ ។ ហើយអ្នករាល់គ្នាត្រូវនិយាយក្នុងចិត្តថា---សូមឲ្យព្រះទ្រង់ជំនុំជំរះរវាងអ្នក និងខ្ញុំ ហើយសងអ្នកតាមអំពើដែលអ្នកធ្វើចុះ » ( គ. និង ស. 64:10--11 ) ។ បន្ទាប់មក យើងត្រូវបំភ្លេចពីបញ្ហានោះទាំងស្រុង ហើយទុកឲ្យព្រះអម្ចាស់ដោះស្រាយបញ្ហានោះពីពេលនោះចុះ ប្រសិនបើយើងប្រាថ្នាចង់បានជាសះស្បើយ ។

« ព្រះអម្ចាស់ទ្រង់ពុំដែលនាំយើងទៅក្នុងសេចក្ដីល្បួងឡើយ » ( បទជម្រើសនានាចេញពីការបកប្រែព្រះគម្ពីរប៊ីបដោយ យ៉ូសែប ស៊្មីធ, ម៉ាថាយ 6:14 ក្នុងសេចក្ដីណែនាំដល់បទគម្ពីរទាំងឡាយ ) ។ ដូច្នេះ ក្នុងការអធិស្ឋានរបស់យើង យើងអាចចាប់ផ្ដើមដំណើរការការពារដោយពាក់នូវគ្រឿងសឹកនៃព្រះ ( សូមមើល អេភេសូរ 6:11; គ. និង ស. 27:15 ) ដោយសម្លឹងឆ្ពោះទៅថ្ងៃខាងមុខ ហើយសុំជំនួយសម្រាប់ការណ៍ដ៏គួរឲ្យភ័យខ្លាចទាំងឡាយ ដែលយើងអាចនឹងប្រឈមមុខជាមួយ ។ មិត្តទាំងឡាយ សូមកុំភ្លេចទូលដល់ព្រះអម្ចាស់ឲ្យការពារ និងគង់នៅជាមួយអ្នកផង ។

« ដ្បិតរាជ្យព្រះចេស្ដា និងសិរីល្អជារបស់ផងទ្រង់ នៅអស់កល្បជានិច្ច » ( ម៉ាថាយ 6:13 ) ។ ជាការណ៍ល្អម្ល៉េះ ដែលព្រះយេស៊ូវបានបញ្ចប់ការអធិស្ឋាននេះ ដោយការសរសើរតម្កើងដល់ព្រះម្ដងទៀត ហើយបង្ហាញគារវភាព និងការស្ដាប់បង្គាប់របស់ទ្រង់ចំពោះព្រះវរបិតា ។ ពេលយើងជឿជាប្រាកដថា ព្រះគ្រប់គ្រង់នគរទ្រង់ ហើយថាទ្រង់មានអំណាច និងសិរីល្អគ្រប់យ៉ាង នោះយើងកំពុងទទួលស្គាល់ថា ទ្រង់ពិតជាគ្រប់គ្រង ថាទ្រង់ស្រឡាញ់យើង

ដោយក្ដីស្រឡាញ់ឥតខ្ចោះ ហើយថាទ្រង់ចង់ឲ្យយើងរីករាយ ។ ខ្ញុំបានឃើញថា អាថ៌កំបាំងមួយសម្រាប់ជីវិតដែលពេញដោយអំណរនោះ គឺដើម្បីទទួលស្គាល់ថា ការធ្វើអ្វីៗតាមរបៀបព្រះអម្ចាស់ នឹងធ្វើឲ្យយើងរីករាយជាងការធ្វើអ្វីៗតាមរបៀបខ្ញុំ ។

មានគ្រោះថ្នាក់មួយ ដែលបុគ្គលម្នាក់អាចមិនមានអារម្មណ៍ស័ក្តិសមគ្រប់គ្រាន់ដើម្បីអធិស្ឋាន ។ គំនិតនេះមកពីវិញ្ញាណអាក្រក់ ដែលជាអ្នកបង្រៀនយើងមិនឲ្យអធិស្ឋាន ( សូមមើល នីហ្វៃទី2 32:8 ) ។ វាដូចជាសោកនាដកម្មមួយ ក្នុងការគិតថា យើងមានបាបច្រើនពេក មិនអាចអធិស្ឋានទេ គឺដូចជាអ្នកជម្ងឺឈឺធ្ងន់ម្នាក់ដែលជឿថា គាត់ឈឺធ្ងន់ជ្រុលពេកនឹងទៅជួបគ្រូពេទ្យទៅហើយ !

យើងមិនត្រូវគិតថា ការអធិស្ឋានណាក៏ដោយ មិនថាស្មោះត្រង់ប៉ុណ្ណាទេ នោះនឹងមានប្រសិទ្ធភាពណាស់ បើយើងគ្រាន់តែអធិស្ឋានប៉ុណ្ណោះនោះ ។ យើងមិនត្រូវគ្រាន់តែអធិស្ឋានប៉ុណ្ណោះទេ យើងត្រូវតែរស់នៅតាមនោះដែរ ។ ព្រះអម្ចាស់សព្វព្រះទ័យជាង ចំពោះអ្នកណាដែលអធិស្ឋាន ហើយធ្វើ ជាជាងអ្នកដែលគ្រាន់តែអធិស្ឋានតែមួយមុខប៉ុណ្ណោះ ។ គឺដូចជាថ្នាំពេទ្យអញ្ចឹង ការអធិស្ឋានមានប្រសិទ្ធភាពបាន លុះត្រាតែយើងប្រើវាដូចដែលបានណែនាំប៉ុណ្ណោះ ។

ពេលខ្ញុំនិយាយថា ការអធិស្ឋានជាឯកសិទ្ធមួយដ៏ផ្អែមល្ហែម វាមិនត្រឹមតែដោយព្រោះខ្ញុំមានអំណរគុណ ដែលបានទូលទៅព្រះវរបិតា និងមានព្រះវិញ្ញាណទ្រង់ ពេលខ្ញុំអធិស្ឋានប៉ុណ្ណោះទេ ។ វាក៏ដោយព្រោះទ្រង់ពិតជាឆ្លើយ និងមានបន្ទូលមកកាន់យើងផងដែរ ។ ពិតណាស់ របៀបដែលទ្រង់មានបន្ទូលមកយើង គឺមិនមែនដោយសម្លេងមួយដែលយើងឮទេ ។

ប្រធាន បិយដ៍ យេ ផាកកឺ បានពន្យល់ថា ៖ « សម្លេងដ៏ផ្អែមល្ហែម និងស្ងប់ស្ងៀមនៃការបំផុសគំនិតមកជាអារម្មណ៍មួយ ជាជាងសូរសម្លេងមួយ ។ ប្រាជ្ញាដ៏បរិសុទ្ធអាចត្រូវបាននិយាយនៅក្នុងគំនិត... ។ ការណែនាំនេះមកជាគំនិត ជាអារម្មណ៍ តាមរយៈការបំផុស និងចំណាប់អារម្មណ៍ » ( « Prayer and Promptings » *Liahona* និង *Ensign* ខែ វិច្ឆិកា ឆ្នាំ 2009 ទំព័រ 44 ) ។

ជួនកាល យើងហាក់ពុំទទួលចម្លើយសម្រាប់ការអធិស្ឋានដ៏ស្មោះត្រង់ និងដោយប្រឹងប្រែងរបស់យើងសោះ ។ វាត្រូវការជំនឿ ដើម្បីចងចាំថា ព្រះអម្ចាស់ឆ្លើយតបតាមពេល និងរបៀបរបស់ទ្រង់ ដើម្បីប្រទានពរក្នុងរបៀបល្អបំផុតដល់យើង ។ ឬ ពេលយើងកាន់តែគិតពីវា ជាញឹកញាប់ យើងនឹងយល់ថា យើងដឹងយ៉ាងច្បាស់រួចទៅហើយ នូវអ្វីដែលយើងគួរធ្វើ ។ សូមកុំបាក់ទឹកចិត្ត ប្រសិនបើវាមិនបានសម្រេចភ្លាមៗនោះ ។ ដូចជាការរៀនភាសាបរទេសមួយដែរ វាត្រូវការការអនុវត្ត និងការប្រឹងប្រែង ។ សូមដឹងថា អ្នកអាចរៀនភាសានៃព្រះវិញ្ញាណ ហើយពេលអ្នកធ្វើដូច្នោះ វានឹងផ្ដល់ដល់អ្នកនូវជំនឿ និងអំណាចដ៏អស្ចារ្យក្នុងសេចក្ដីសុចរិត ។

ខ្ញុំស្រឡាញ់ដំបូន្មានរបស់ព្យាការីជាទីស្រឡាញ់របស់យើង ប្រធាន ថូម៉ាស អេស ម៉នសុន ដែលបានមានប្រសាសន៍ថា ៖ « ដល់អស់អ្នកណាដែលអាចឮសម្លេងរបស់ខ្ញុំ ដែលកំពុងពុះពារជាមួយនឹងឧបសគ្គ និងការពិបាកទាំងឡាយ ទោះធំ ឬតូច ការអធិស្ឋានជាអ្នកផ្ដល់កម្លាំងខាងវិញ្ញាណ វាជាអ្វីដែលនាំទៅកាន់ភាពសុខសាន្ត ។ ការអធិស្ឋានជាមធ្យោបាយ ដែលយើងអាចខិតជិតព្រះវរបិតា ដែលទ្រង់ស្រឡាញ់យើង ។ សូមទូលទៅកាន់ទ្រង់ក្នុងការអធិស្ឋាន ហើយបន្ទាប់មកស្ដាប់ការឆ្លើយតប ។ អព្ភូតហេតុកើតឡើងតាមរយៈការអធិស្ឋាន » ( « Be Your Best Self » *Liahona* និង *Ensign* ឧសភា ឆ្នាំ 2009 ទំព័រ 68 ) ។

ខ្ញុំមានអំណរគុណយ៉ាងជ្រាលជ្រៅចំពោះឯកសិទ្ធក្នុងការទៅកាន់ព្រះវរ-បិតាសួគ៌ដ៏បរិសុទ្ធរបស់ខ្ញុំដោយការអធិស្ឋាន ។ ខ្ញុំមានអំណរគុណសម្រាប់ពេលវេលាឥតគណនា ដែលទ្រង់បានឮ និងឆ្លើយតបដល់ខ្ញុំ ។ ដោយព្រោះទ្រង់ឆ្លើយតបខ្ញុំ រួមទាំងពេលខ្លះ នៅក្នុងរបៀបព្យាករ និងអព្ភូតហេតុ នោះខ្ញុំដឹងថា ទ្រង់មានព្រះជន្មរស់ ។ ខ្ញុំក៏សូមថ្លែងទីបន្ទាល់ដ៏រាបទាបថា ព្រះយេស៊ូវ ជាព្រះរាជបុត្រាដ៏បរិសុទ្ធរបស់ទ្រង់ ជាអង្គសង្គ្រោះដែលមានព្រះជន្មរស់ ។ នេះជាសាសនាចក្រ និងនគរទ្រង់ នៅលើផែនដី កិច្ចការនេះគឺពិត ។ ថូម៉ាស អេស ម៉នសុន ដែលយើងអធិស្ឋានយ៉ាងក្លៀវក្លាសម្រាប់លោកនោះ ជាព្យាការីរបស់ទ្រង់ ខ្ញុំថ្លែងទីបន្ទាល់នូវការណ៍ទាំងអស់នេះ ដោយភាពប្រាកដទាំងស្រុង ក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន ។

កំណត់ចំណាំ

1. សូមមើល « Priorities in Prayer » Francis M. Lyman, YMMIA Conference ថ្ងៃទី 5 ខែ មិថុនា ឆ្នាំ 1892, Brian H. Stuy, ed., Collected Discourses, 5 vols., ទំព័រ 3; B.H. Roberts, Seventy′s Course in Theology, 4, ទំព័រ 120 «Encyclopedia of Mormonism, ទំព័រ 1118; « Mormon Doctrine » Bruce R. McConkie ទំព័រ 583 ។